# មេរៀនទី ៣៦: ព្រះជាម្ចាស់តាំងសញ្ញាជាមួយលោកអាប់រ៉ាម

## លោកុប្បត្តិ ១៥:១-១៨

**គោលបំណង៖** ព្រះជាម្ចាស់ជ្រាបដឹងគ្រប់ការទាំងអស់។

**ខគម្ពីរចងចាំ៖ ទំនុកតម្កើង១:៦** *“ដ្បិតព្រះយេហូវ៉ាទ្រង់ជ្រាបផ្លូវរបស់មនុស្សសុចរិតតែផ្លូវរបស់មនុស្ស អាក្រក់នឹងវិនាសទៅវិញ។”*

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**

ផែនការរបស់ព្រះគឺល្អឥតខ្ចោះ។ យើងអរព្រះគុណដល់ព្រះសម្រាប់អង្គព្រះយេស៊ូវដែលបានបង្ហាញនូវផែនការរបស់ព្រះសម្រាប់យើង និងជួយយើងឱ្យមើលឃើញនៅពេលដែលយើងបានដើរតាមការណែនាំរបស់ទ្រង់ ព្រះអង្គតែងតែគង់ជាមួយយើងគ្រប់ជំហានទាំងអស់។ តើនៅពេលណាដែលធ្វើឱ្យអ្នកទទួលស្គាល់ថាអ្វីដែលអ្នកធ្វើគឺជាផែនការរបស់ព្រះ? នៅពេលដែលព្រះបង្ហាញផ្លូវដល់អ្នក នោះតែងតែធ្វើឱ្យអ្នកមានអារម្មណ៍ថាពិសេសបំផុត។ ពេលខ្លះវាមានភាពភ័យខ្លាច ប្រសិនបើអ្នកមិនប្រាកដថាអ្នកអាចធ្វើតាមអ្វីដែលព្រះចង់ឱ្យយើងធ្វើ។ ប៉ុន្តែនៅពេលដែលព្រះទ្រង់ដឹកនាំយើង ទ្រង់នឹងជួយយើងឱ្យយកឈ្នះនូវការទាំងនោះ។ សូមចែកចាយជាមួយសិស្សរបស់អ្នកពីរបៀបដែលព្រះបានដឹកនាំ និងពីអារម្មណ៍ដែលអ្នកមានក្នុងការដើរតាមទ្រង់។ សូមលើកទឹកចិត្តពួកគេថាផែនការរបស់ព្រះគឺពិតជាពិសេសណាស់ ពីព្រោះព្រះអង្គទ្រង់ជ្រាបគ្រប់ការទាំងអស់។

**ចំរៀង៖** ១. ព្រះយេស៊ូវគ្រីស្ទជាព្រះអម្ចាស់ ២.តើអ្នកណាជាម្ចាស់នៃខ្ញុំ ៣. ទ្រង់មិនដែលខាន

**១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបើក)*

**២. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**៣. ល្បែងកំសាន្ត «ទះភ្លៅ ១ ២ ៣ និយាយឈ្មោះ»**




១. ឲ្យកុមារអង្គុយជារង្វង់
២. គ្រូនឹងនិយាយ “១ ២ ៣” ព្រមទាំងទះភ្លៅរបស់គាត់ផងក្នុងពេលដដែលនោះ ហើយចង្អុលទៅកុមារណាម្នាក់រួចនិយាយឈ្មោះរបស់កុមារនោះ
៣. កុមារដែលគ្រូហៅនោះនឹងទះភ្លៅរបស់គេ ក្នុងពេលតែមួយនោះ កុមារនោះត្រូវនិយាយ “១ ២ ៣” ហើយចង្អុលទៅកុមារណាម្នាក់ព្រមទាំងនិយាយឈ្មោះរបស់កុមារនោះផង។
៤. ប្រសិនបើកុមារណាម្នាក់មិនអាចនិយាយឈ្មោះរបស់កុមារដែលគេចង្អុលនោះទេ នោះគេនឹងចាញ់ល្បែងនេះ
៥. បន្តលេងល្បែងនេះរហូតដល់នៅសល់កុមារតែម្នាក់ជាអ្នកឈ្នះ។
៦. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា យើងប្រហែលជាមិនចងចាំឈ្មោះរបស់កុមារគ្រប់គ្នានៅក្នុងបន្ទប់នេះទេ ប៉ុន្តែព្រះស្គាល់ឈ្មោះរបស់យើងគ្រប់ៗគ្នា។ នេះគឺព្រោះតែព្រះជ្រាបដឹងគ្រប់យ៉ាងទាំងអស់។

## ៤. ការណែនាំមេរៀន

តើអ្នកធ្លាប់មិនរក្សាការសន្យារបស់អ្នកដែរឬទេ? តើអ្នកមានអារម្មណ៍ដូចម្ដេចនៅពេលដែលនរណាម្នាក់មិនរក្សាការសន្យារបស់គេនោះ? នៅពេលដែលព្រះធ្វើការសន្យា ព្រះអង្គតែងតែរក្សាការសន្យារបស់ទ្រង់ជានិច្ច។ ថ្ងៃនេះយើងនឹងរៀនពីការសន្យារបស់ព្រះជាមួយលោកអាប់រ៉ាម។ តើអ្នកគិតថាព្រះនឹងរក្សាការសន្យារបស់ទ្រង់ជាមួយលោកអាប់រ៉ាមដែរឬទេ?

## ៥. រឿងនៅក្នុងព្រះគម្ពីរ

អាប់រ៉ាមគឺជាបុរសដែលទុកចិត្ត និងតែងតែស្ដាប់បង្គាប់ព្រះ។ គាត់បានរៀបការជាមួយស្ត្រីម្នាក់ដែលមានឈ្មោះថាសារ៉ាយ។ នៅពេលដែលអាប់រ៉ាមមានអាយុ ៧៥ឆ្នាំ ព្រះបានសន្យាជាមួយគាត់ថានឹងប្រទានទឹកដីទៅកូនចៅរបស់អាប់រ៉ាម ប៉ុន្តែអាប់រ៉ាមមិនទាន់មានកូននៅឡើយទេ។ ទោះជាយ៉ាងណាក៏គាត់នៅតែទុកចិត្តព្រះ។

មួយរយៈក្រោយមកនៅយប់មួយព្រះក៏បានលេចឡើងនៅចំពោះអាប់រ៉ាម។ លើកនេះព្រះបានមានបន្ទូលទៅកាន់អាប់រ៉ាមថា **លោកុប្បត្តិ ១៥:១** “អាប់រ៉ាមអើយ កុំខ្លាចអ្វីឡើយ! យើងនឹងធ្វើជាខែលការពារអ្នក អ្នកនឹងទទួលរង្វាន់យ៉ាងធំ។” ប៉ុន្តែអាប់រ៉ាមមានការខកចិត្ត ដោយព្រោះតែគាត់នៅមិនទាន់មានកូន បើទោះបីជាព្រះបានសន្យាជាមួយគាត់ក៏ដោយ។ គាត់បាននិយាយទៅព្រះថា តើរង្វាន់ដ៏ធំនោះមានប្រយោជន៍អ្វីបើគាត់មិនមានកូនចៅក្នុងការទទួលមរតកនោះផង។ ហើយព្រះក៏បានប្រាប់អាប់រ៉ាមថា គាត់នឹងមានកូនម្នាក់យ៉ាងពិតប្រាកដ គឺជាកូនប្រុសដែលត្រូវទទួលមរតកគ្រប់យ៉ាងពីគាត់។

បន្ទាប់មកព្រះក៏បាននាំអាប់រ៉ាមទៅក្រៅ ហើយក៏មានបន្ទូលប្រាប់អាប់រ៉ាមថា **លោកុប្បត្តិ ១៥:៥** “ចូរងើយមើលទៅលើមេឃ ហើយរាប់ចំនួនផ្កាយមើល៍ តើអ្នកអាចរាប់អស់ទេ?” ហើយទ្រង់ក៏បានមានបន្ទូលទៅគាត់ទៀតថា “ពូជពង្សរបស់អ្នកក៏នឹងមានចំនួនច្រើនដូចផ្កាយទាំងនោះដែរ។”

នៅពេលដែលអាប់រ៉ាមបានឮដូច្នេះគាត់បានជឿដល់ព្រះ។ អាប់រ៉ាមដឹងថាព្រះជ្រាបគ្រប់ការទាំងអស់។ គាត់ដឹងច្បាស់ថាគាត់អាចទុកចិត្តព្រះបាន ដូច្នេះគាត់បានដាក់សេចក្ដីជំនឿរបស់គាត់ទាំងស្រុងទៅលើទ្រង់ ហើយអ្វីដែលព្រះទ្រង់បានសន្យាគឺក្លាយជាការពិតមែន។ នៅពេលវេលាមកដល់ អាប់រ៉ាមក៏មានកូនប្រុសម្នាក់។ កូននោះធំឡើងគាត់បានមានកូនចៅជាច្រើនថែមទៀត។ កន្លងមកជាច្រើនឆ្នាំ ពូជពង្សរបស់អាប់រ៉ាមមានចំនួនកាន់តែច្រើនដូចជាផ្កាយនៅលើមេឃពិតមែន។

សាច់រឿងនៅក្នុងព្រះគម្ពីរថ្ងៃនេះ ព្រះបានប្រាប់អាប់រ៉ាមពីអ្វីដែលនឹងកើតឡើងចំពោះគាត់នៅពេលអនាគត។ តើវាមិនមែនជារឿងអស្ចារ្យទេឬដែលយើងអាចដឹងពីអនាគតរបស់យើងនោះ? ប៉ុន្តែគឺមានតែព្រះប៉ុណ្ណោះដែលជ្រាបគ្រប់ការទាំងអស់បាន។ ព្រះបានប្រាប់អាប់រ៉ាមថា ទ្រង់នឹងប្រទានពរឱ្យគាត់មានកូនប្រុសម្នាក់ និងមានពូជពង្សបន្តជាចៅ ចៅទួតច្រើនដូចជាផ្កាយលើមេឃ។ មនុស្សគ្រប់រូបទាំងនោះសុទ្ធសឹងជាផ្នែកមួយនៃផែនការរបស់ព្រះ។ នេះគឺមានន័យថាយើងរាល់គ្នាក៏ជាផែនការរបស់ព្រះដែរ។ មិនមានមនុស្សណាម្នាក់កើតមកដោយមិនមែនជាផែនការរបស់ទ្រង់នោះឡើយ! ព្រះមានផែនការសម្រាប់មនុស្សគ្រប់គ្នាដែលបានទុកចិត្តដល់ទ្រង់។

ព្រះជាម្ចាស់ក៏មានផែនការសម្រាប់បុត្រារបស់ទ្រង់ផងដែរគឺព្រះយេស៊ូវ។ នៅពេលដែលព្រះយេស៊ូវបានយាងមកលើផែនដីដោយយកកំណើតជាទារកម្នាក់នោះ ព្រះទ្រង់ជ្រាបថាពេលដែលព្រះយេស៊ូវធំឡើង ទ្រង់នឹងបង្រៀនមនុស្សឱ្យចេះស្រឡាញ់គ្នាទៅវិញទៅមក និងជួយសង្គ្រោះដល់អស់អ្នកណាដែលជឿថាទ្រង់អាចជួយគេឱ្យរួចពីបាបបាន។ ព្រះមិនមែនមានផែនការសម្រាប់តែព្រះយេស៊ូវប៉ុណ្ណោះទេ ប៉ុន្តែទ្រង់មានផែនការសម្រាប់មនុស្សលោកគ្រប់គ្នា។ យើងម្នាក់ៗសុទ្ធតែមានសារៈសំខាន់សម្រាប់ផែនការរបស់ព្រះ។ ព្រះអង្គចង់ឱ្យយើងទុកចិត្ត និងដើរតាមផែនការរបស់ទ្រង់ ពីព្រោះទ្រង់ជាព្រះដែលជ្រាបគ្រប់ការទាំងអស់ ហើយព្រះអង្គដឹងថានឹងមានអ្វីដែលត្រូវកើតឡើងផងដែរ។ ព្រះអង្គទ្រង់ស័ក្តិសមឱ្យយើងថ្វាយបង្គំទ្រង់ពីព្រោះទ្រង់ជ្រាបគ្រប់ការទាំងអស់។ សូមឱ្យយើងបានថ្លែងអំណរព្រះគុណដល់ទ្រង់ដែលទ្រង់បានជ្រាបគ្រប់ការទាំងអស់។

## ៦. សំនួរពិភាក្សា

១. ហេតុអ្វីបានជាអាប់រ៉ាមមានការខកចិត្ត? *គាត់មិនមានកូនដូចគេ*

២. តើព្រះបានសន្យាអ្វីជាមួយនឹងអាប់រ៉ាម? *ពូជពង្សរបស់អ្នកក៏នឹងមានចំនួនច្រើន ដូចផ្កាយនៅលើមេឃ*

៣. តើព្រះអាចប្រាប់ពីអនាគតរបស់អាប់រ៉ាមបានយ៉ាងដូចម្តេច? *ពីព្រោះទ្រង់ជ្រាបគ្រប់ការទាំងអស់*

៤. តើហេតុផលអ្វីដែលធ្វើឱ្យយើងអាចទុកចិត្តនិងដើរតាមទ្រង់បាន? *ទ្រង់ជ្រាបគ្រប់ការទាំងអស់*

## ៧. ល្បែងកំសាន្ត «ចេក ប៉ោម ក្រូច»



១. ឲ្យកុមារឈរជារង្វង់ហើយដាក់ដៃលើស្មាបន្តគ្នា

២. នៅពេលដែលគ្រូនិយាយពាក្យថា "ចេក" កុមារទាំងអស់ត្រូវលោតទៅមុខ នៅពេលដែលគ្រូនិយាយពាក្យថា "ប៉ោម"ពួកគេត្រូវលោតថយក្រោយ ហើយនៅពេលដែលគ្រូនិយាយពាក្យថា "ក្រូច" ពួកគេត្រូវលោតត្រឡប់បែរមកកាន់ស្មាអ្នកដែលនៅពីក្រោយគេវិញម្តង។

៣. កុមារណាដែលធ្វើខុស នោះគេនឹងមិនអាចលេងល្បែងនេះបានទេ។ បន្តលេងល្បែងនេះ រហូតដល់នៅសល់កុមារតែ ៣ ទៅ ៥នាក់។

៤. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា មានកុមារខ្លះមានការភ័ន្តច្រឡំនៅពេលលេងល្បែងនេះ ពីព្រោះពួកគេមិនដឹងថាគេត្រូវធ្វើអ្វីនោះទេ។ ប៉ុន្តែព្រះគឺមិនដែលមានការភ័ន្តច្រឡំនោះទេ ពីព្រោះទ្រង់ជ្រាបដឹងគ្រប់យ៉ាង។

## ៨. ខគម្ពីរចងចាំ ទំនុកតម្កើង១:៦

## ៩. ហាត្ថកម្ម សូមផាត់ពណ៌- **«ព្រះជាម្ចាស់ចងសម្ព័ន្ធមេត្រីជាមួយលោកអាប់រ៉ាម»**

## ១០. ចំរៀង *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

## ១១. អធិស្ឋាន *(សូមនាំកុមារអធិស្ឋានបិទ)*

# ព្រះជាម្ចាស់ចងសម្ព័ន្ធមេត្រីជាមួយលោកអាប់រ៉ាម



លោកុប្បត្តិ ១៥:៥ “ចូរងើយមើលទៅលើមេឃ ហើយរាប់ចំនួនផ្កាយមើល តើអ្នកអាចរាប់អស់ទេ?” ហើយទ្រង់ក៏បានមានបន្ទូល ទៅគាត់ទៀតថា “ពូជពង្សរបស់អ្នកក៏នឹងមានចំនួនច្រើន ដូចផ្កាយទាំងនោះដែរ។”